ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងទេសចរណ៍**
**លេខ** ០១៤ សរណន

ថ្ងៃ ពុធ ១០រោច ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស២៥៦១
រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ មករា ឆ្នាំ២០១៨

# សារាចរណែនាំ
## ស្តីពី
## នីតិវិធីនៃចលនាប្រឡងប្រណាំងបដិសណ្ឋារកិច្ចល្អក្នុងវិស័យទេសចរណ៍លើកទី១

ដើម្បីទទួលបានលទ្ធផលវាយតម្លៃសម្រាប់ចលនាប្រឡងប្រណាំង **"បដិសណ្ឋារកិច្ចល្អក្នុងវិស័យទេសចរណ៍"** មានលក្ខណៈត្រឹមត្រូវ និងមានតម្លាភាព ប្រសិទ្ធភាពខ្ពស់ សំដៅចូលរួមលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាបដិសណ្ឋារកិច្ចល្អរបស់មូលដ្ឋានអាជីវកម្មទេសចរណ៍ជូនភ្ញៀវទេសចរប្រកបដោយបដិសណ្ឋារកិច្ចល្អ និងផ្តល់ភាពកក់ក្តៅ។

**ក្រសួងទេសចរណ៍** សូមណែនាំពីនីតិវិធីនៃចលនាប្រឡងប្រណាំងបដិសណ្ឋារកិច្ចល្អក្នុង វិស័យទេសចរណ៍ ដល់មន្ទីរទេសចរណ៍រាជធានី-ខេត្ត ប្រតិបត្តិករទេសចរណ៍ និងសាធារណជនមេត្តាជ្រាបដូចខាងក្រោមនេះ៖

- **ដំណាក់កាលទី១៖** ប្រគល់ភារកិច្ចជូនមន្ទីរទេសចរណ៍រាជធានី-ខេត្ត ជ្រើសរើសបេក្ខភាពដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីចូលរួមក្នុងចលនាប្រឡងប្រណាំងបដិសណ្ឋារកិច្ចល្អក្នុងវិស័យទេសចរណ៍ស្របលក្ខណៈវិនិច្ឆ័យនៃ**គោលការណ៍ណែនាំស្តីពីបដិសណ្ឋារកិច្ចល្អក្នុងវិស័យទេសចរណ៍**។
- **ដំណាក់កាលទី២៖** មន្ទីរទេសចរណ៍រាជធានី-ខេត្ត ត្រូវបញ្ជូនព័ត៌មានទាក់ទងនឹងបេក្ខភាពដែលជ្រើសរើសរួចមកអគ្គនាយកដ្ឋានគ្រប់គ្រងឧស្សាហកម្មទេសចរណ៍នៃក្រសួងទេសចរណ៍។
- **ដំណាក់កាលទី៣៖** បេក្ខភាពដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តម្រូវឱ្យ៖
  - បំពាក់នូវបញ្ជរ QR-Code សម្រាប់ដាក់លើតុ
  - វិក័យបត្រដែលមានភ្ជាប់ QR Code បដិសណ្ឋារកិច្ចល្អ
  - ប័ណ្ណណែនាំ (Brochure) ពីនីតិវិធីវាយតម្លៃបដិសណ្ឋារកិច្ចល្អ
  - ឯកសារផ្សព្វផ្សាយនានាដែលមានភ្ជាប់នូវ QR Code វាយតម្លៃបដិសណ្ឋារកិច្ចល្អក្នុងវិស័យទេសចរណ៍ដែលអនុញ្ញាតឱ្យប្រជាពលរដ្ឋ និងភ្ញៀវទេសចរចូលរួមផ្តល់មតិយោបល់។
- **ដំណាក់កាលទី៤៖** អគ្គនាយកដ្ឋានគ្រប់គ្រងឧស្សាហកម្មទេសចរណ៍នឹងធ្វើសម្រង់បេក្ខភាព (Shortlist) ដោយផ្អែកលើលក្ខណៈតម្រូវឱ្យមានភ្ញៀវទេសចរណ៍ចូលរួមផ្តល់មតិយោបល់ លើការបម្រើសេវាបដិសណ្ឋារកិច្ចល្អរបស់ខ្លួនយ៉ាងតិច **២៥០មតិយោបល់** ទើបត្រូវបានជ្រើសរើសជា**បេក្ខភាពផ្លូវការ**ក្នុងការប្រកួតប្រជែងបដិសណ្ឋារកិច្ចល្អក្នុងវិស័យទេសចរណ៍នេះ។
- **ដំណាក់កាលទី៥៖** បេក្ខភាពផ្លូវការដែលជាប់(Shortlist) ទាំងអស់នឹងត្រូវធ្វើការផ្សព្វផ្សាយលើហ្វេកប៊ុក (FACEBOOK) ផ្លូវការរបស់ក្រសួងទេសចរណ៍ (ភ្ជាប់នឹងប្រព័ន្ធវាយតម្លៃ Online បដិសណ្ឋារកិច្ចល្អ **www.cambodiabesthospitality.org**) ដើម្បីអនុញ្ញាតឱ្យប្រជាពលរដ្ឋ និងភ្ញៀវទេសចរចូលរួមផ្តល់មតិយោបល់វាយតម្លៃ (Vote) លើការបម្រើសេវាប្រកបដោយបដិសណ្ឋារកិច្ចល្អរបស់ខ្លួន

ជាចុងក្រោយបន្ថែមទៀត។ ដើម្បីធ្វើការជ្រើសរើសមូលដ្ឋានអាជីវកម្មទេសចរណ៍ឆ្នើមប្រចាំឆ្នាំក្នុងការផ្តល់សេវាបដិសណ្ឋារកិច្ចល្អដល់ភ្ញៀវទេសចរណ៍របស់ខ្លួន។

❖ **ដំណាក់កាលទី៦៖** ក្រសួងទេសចរណ៍ នឹងរៀបចំរបាយការណ៍ចុងក្រោយ និងឈានទៅប្រកាសលទ្ធផលជ័យលាភី **“បដិសណ្ឋារកិច្ចល្អក្នុងវិស័យទេសចរណ៍” លើកទី១ នៅខែវិច្ឆិកា ឆ្នាំ២០១៨។**

អាស្រ័យហេតុនេះ សូម **មន្ទីរទេសចរណ៍រាជធានី-ខេត្ត និងប្រតិបត្តិករទេសចរណ៍ទាំងអស់**ជ្រាប និងចូលរួមអនុវត្តសារាចរណែនាំនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**រដ្ឋមន្ត្រី**

**ថោង ខុន**

**<u>ចម្លងជូន៖</u>**

-មន្ទីរទេសចរណ៍រាជធានី-ខេត្ត

*“ដើម្បីមុខការអនុវត្ត”*

- ឯកសារ-កាលប្បវត្តិ